00819418

002/19-09-2007-ECCC/TC
E1/73

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 06 / 2012
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent charge du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ១៧ ខែ ឧសភា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៦១

រៀបចំដោយ: សែ កុលវុឌ្ឍី និង Faiza ZOUAKRI

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោកស្រី Faiza ZOUAKRI, លោកស្រី សែ កុលវុឌ្ឍី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វេង ហ៊ត់, លោក Keith RAYNOR, លោក Tarik ABDULHAK។ |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI, លោក Michiel PESTMAN ។ |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS។ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE ។ |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោក គឹម ម៉េងឃី, លោក ហុង គឹមសួន, លោក វ៉ែន ពៅ, លោក Pascal AUBOUIN, លោក Barnabé NEKUIE. |
| សាក្សី៖ ពាន ឃាន (TCW-504) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា Alexandra PRASSOLOFF , លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី) |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.៤៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤០ | បញ្ចប់ម៉ោង៖ ១១.00 |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.00 |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៥ ម៉ោង និង ៣០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការបន្តតាំងសំណួរទៅសាក្សី ពាន ឃាន (TCW-504) | សហព្រះរាជអាជ្ញា | ៩.១០ | ១០.៤០ |
| | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១១.00 | ១២.០៥ |
| | មេធាវីការពារក្តី នួន ជា | ១៣.៣៥ | ១៥.៣៥ |
| | មេធាវីការពារក្តី អៀង សារី | ១៥.៣៥ | ១៥.៥0 |
| | មេធាវីការពារក្តី ខៀវ សំផន | ១៥.៥0 | ១៦.៤៥ |
| សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្តី អៀង សារី | ១០.៤០ | ១០.៤០ |
| | មេធាវីការពារក្តី នួន ជា | ១២.០៥ | ១២.០៥ |
| ការជូនដំណឹងអំពីការបញ្ជូនជនជាប់ចោទ អៀង សារី ទៅ | មេធាវីការពារក្តី អៀង សារី | ១៤.00 | ១៤.00 |

| | | | |
|---|---|---|---|
| មន្ទីរពេទ្យ | | | |
| ការជំទាស់ទាក់ទងនឹងការប្រើប្រាស់ឯកសារមកដេញដោលសាក្សី | សហព្រះរាជអាជ្ញា<br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>មេធាវីការពារក្ដី នួន ជា<br>អង្គជំនុំជម្រះ | ១៤.៣០ | ១៥.៣០ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការបន្តតាំងសំណួរទៅសាក្សី ពាន ឃាន**

សហព្រះរាជអាជ្ញាបានបន្តតាំងសំណួរទៅសាក្សី ពាន ឃាន។ បន្ទាប់មកមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីការពារក្ដី នួន ជា មេធាវីការពារក្ដី អៀង សារី និងមេធាវីការពារក្ដី ខៀវ សំផន បានតាំងសំណួរទៅសាក្សី ពាន ឃាន។

**សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់ខ្លួន បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ ដោយចូលរួមសវនាការពីបន្ទប់រង់ចាំខាងក្រោមបន្ទប់សវនាការ។ អង្គជំនុំជម្រះអនុញ្ញាតិតាមសំណើ។

**ការជូនដំណឹងអំពីការបញ្ជូនជនជាប់ចោទ អៀង សារីទៅមន្ទីរពេទ្យ**

មេធាវីការពារក្ដី អៀង សារី បានជូនដំណឹងថា ជនជាប់ចោទ អៀង សារី មានបញ្ហាសុខភាពធ្ងន់ធ្ងរដែលត្រូវបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យជាបន្ទាន់ ប៉ុន្តែជនជាប់ចោទយល់ព្រមឱ្យមានការបន្តសវនាការដោយអវត្តមានជនជាប់ចោទ។ អង្គជំនុំជម្រះបានអនុញ្ញាតិឱ្យអៀង សារីទៅព្យាបាលនៅមន្ទីរពេទ្យ នឹងសម្រេចឱ្យមានការបន្តដំណើរការនីតិវិធី ដោយអវត្តមានជនជាប់ចោទ ផ្អែកតាមវិធាន ៨១.៥។ អង្គជំនុំជម្រះបានសម្រេចថា អង្គជំនុំជម្រះនឹងពិនិត្យរបាយការណ៍ពេទ្យប្រចាំនៅ អ.វ.ត.ក នៅព្រឹកថ្ងៃចន្ទ។

**ការជំទាស់ចំពោះការប្រើប្រាស់ឯកសារមកដេញដោលចំពោះសាក្សី**

សហព្រះរាជអាជ្ញា បានស្នើសុំឱ្យអង្គជំនុំជម្រះបញ្ជាក់អំពីការប្រើប្រាស់បទសម្ភាសន៍របស់បុគ្គលផ្សេងក្នុងអំឡុងពេលដេញដោលទៅលើសាក្សីឯកសារលេខ D224.14។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការបញ្ជាក់អំពីការប្រើប្រាស់ឯកសារនៅពេលដែលសាក្សីបញ្ជាក់ថាខ្លួនមិនដែលបានឃើញឯកសារនេះពីមុនមក។ អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឱ្យ មេធាវីការពារក្ដី នួន ជា ដាក់

(ឯកសារលេខ D224.14 បទសម្ភាសន៍ជាមួយ ព្រំ យ៉េត) នៅចំពោះមុខអង្គជំនុំជម្រះ និងអាចប្រើប្រាស់នៅក្នុងការតាំងសំណួរទៅសាក្សី ដោយហេតុថាបុគ្គលដែលត្រូវបានសម្ភាសន៍នេះមិនមែនជាសាក្សីនៅក្នុងសំណុំរឿងនេះទេ ហើយឯកសារនេះមានតម្លៃជាភស្តុតាងតិចតួចប៉ុណ្ណោះ។ អង្គជំនុំជម្រះបានបញ្ជាក់ថា ប្រសិនបើឯកសារនេះ មិនមានភាពពាក់ព័ន្ធដោយសារតែសាក្សីមិនបានស្គាល់អ្នកដែលបានផ្តល់បទសម្ភាសន៍នោះទេ ឬក៏មិនមែនជាអង្គហេតុដែលត្រូវធ្វើការដេញដោល អង្គជំនុំជម្រះនឹងបញ្ឈប់ការតាំងសំណួរ។

មេធាវីការពារក្តី នួន ជា បានស្នើសុំយកឯកសារ D125/207 មកធ្វើការដេញដោលចំពោះសាក្សី ពាន ឃាន ផងដែរ។ សហព្រះរាជអាជ្ញាបានរំលឹកដល់ភាគីទាំងអស់ថា ឯកសារ D125/207 ត្រូវបានជំទាស់ដោយមេធាវីការពារក្តី អៀង សារី នៅក្នុងឯកសារដែលមានលេខ E131/1/10.19។ អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឱ្យមេធាវីការពារក្តីនួនជាប្រើប្រាស់ឯកសារនេះក្នុងការតាំងសំណួរទៅសាក្សីដោយសារតែមិនមានការជំទាស់ខ្លាំង ទាក់ទងនឹងការប្រើប្រាស់ឯកសារនេះ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/342 | D288/6.68.1 | 00329596-00330129<br>00329596-00330129 | ឧបសម្ព័ន្ធ ១៖ ការពិនិត្យឡើងវិញបញ្ជីអ្នកទោសនៅមន្ទីរស ២១<br>Annex 1: Revised S-21 Prisoner List | P | 00330124 | 00330124 | |
| N/A | E187.1 | 00801768-00801771<br>00089701-00089702<br>00644575-00644576 | ឧបសម្ព័ន្ធ ១៖ បទសម្ភាសន៍ធ្វើឡើងដោយ SOAS ជាមួយ Pean Khean នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៥<br>Annex 1: SOAS interview of Pean Khean, dated 25 July 2005<br>Annexe 1 : Interview de Pean Khean effectué par SOAS le 25 juillet 2005 | P | 00801769 | 00089701 | 00644575 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1604 | 5.39 | 00006757-<br>00006956,<br>00005994-<br>00006184,<br>00005709-<br>00005832,<br>00005844-<br>00005993<br>00776989-<br>00776994,<br>00773088-<br>00773135,<br>00759697-<br>00759708,<br>00096779-<br>00096813,<br>00769830-<br>00769831<br>00766794-<br>00766795,<br>00759975-<br>00759985,<br>00766973-<br>00766978 | ចម្លើយសារភាពនៅ ស២១របស់ កុយ ធួន<br>[Partial T.] S-21 Confession of KOY Thuon<br>[Partial T.] Aveux de KOY Thuon alias KHUON alias THUCH à S-21 | P | 00005994,<br>00006066 | 00769830, | 00766794 |
| E3/435 | D276/6 | 00373446-<br>00373453<br>00375885-<br>00375891<br>00424121-<br>00424127 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពាន ឃាន PEAN Khean<br>Written Record of Interview of PEAN Khean ពាន ឃាន<br>Procès verbal d'audition de témoin PEAN Khean ពាន ឃាន | P | | | |
| E3/1605 | D224.14 | 00658158-<br>00658158<br>00352073-<br>00352073<br>00631370-<br>00631370 | ឧបសម្ព័ន្ធ 00014: SOAS/HRW<br>កិច្ចសម្ភាសន៍របស់ ព្រំ យេត<br>Annex 00014: SOAS/HRW Interview of Prum Yet<br>Annexe 00014: SOAS/HRW interview avec Prum Yet | P | 00658158 | 00352073 | 00631370 |
| E3/1606 | D125/207 | 00242051-<br>00242056<br>00250135-<br>00250141<br>00277305-<br>00277310 | របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះថ្ងៃទី 07-11-2008<br>Report of the Execution of Rogatory Letter, dated 07-11-2008<br>Rapport d' exécution de Commission rogatoire, en date du 07-11-2008 | P | | | |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (១០.៤០) និង នួន ជា (១២.០៥) ចូលរួមដំណើរការសវនាការពីបន្ទប់នៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរមានភ្ជាប់មកជាមួយនឹងកំណត់នេះ)។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២។
- បង្គាប់ឱ្យនាំ សាក្សី TCW-504 ត្រឡប់ទៅកាន់គេហដ្ឋានរបស់គាត់វិញ។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ ចន្ទ ទី ២១ ខែ ឧសភា ឆ្នាំ ២០១២ វេលាម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលវុឌ្ឍី** **Faïza ZAOUKRI**